هدية
HADIYAH



# សេចក្ដីសង្ខេបអំពីរបៀបនៃការធ្វើអ៊ុំរ៉ោះ និងក្បួនច្បាប់របស់វា

ភាសាខ្មែរ

خميرية

HADIYAH هدية

## សេចក្តីសង្ខេបអំពីរបៀបនៃការធ្វើអុំរ៉ោះ និង ក្បួនច្បាប់របស់វា

ការសរសើរ និង លើកតម្កើងចំពោះអល់ឡោះ ជាម្ចាស់នៃពិភពលោក និង សូមសន្តិភាព និងពរជ័យ មានដល់ព្យាការីម៉ូហាំម៉ាត់របស់យើងព្រមទាំងក្រុមគ្រួសារ និង បណ្តាសហាហ្ពាត់ទាំងអស់របស់គាត់ បន្ទាប់មកទៀត៖
នេះគឺជាសារសង្ខេបអំពីរបៀបនៃការធ្វើអុំរ៉ោះក៏ដូចជាច្បាប់បញ្ញត្តិ និងសុជីវធម៌របស់វា ដែលយើងបានព្យាយាមរៀបរាប់អំពីប្រការចម្បងដែលអ្នកធ្វើអុំរ៉ោះចាំបាច់ត្រូវដឹង។
យើងសុំឱ្យអល់ឡោះជាម្ចាស់ប្រទាន់នូវភាពបរិសុទ្ធចំពោះកិច្ចការមួយនេះសម្រាប់ទ្រង់តែមួយគត់ និងក្លាយជាប្រយោជន៍ដល់ប្រជាជនម៉ូស្លីមទាំងអស់គ្នា។
គណៈកម្មការនៃអង្គការបម្រើការមាតិកាសាសនាអ៊ីស្លាមជាភាសានានា

## សេចក្តីផ្តើម

HADIYAH هدية

# ទីមួយ៖ លក្ខខណ្ឌនៃការទទួលយកកិច្ចគោរពសក្ការៈ

## កិច្ចគោរពសក្ការៈមិនត្រូវបានទទួលយកនោះឡើយ លើកលែងតែមានលក្ខខណ្ឌទាំងពីរនេះ៖

### អៀហខ្លើស(ចិត្តស្មោះស)៖

**ការមានចិត្តស្មោះសនៅក្នុងកិច្ចគោរពសក្ការៈចំពោះអល់ឡោះតែម្នាក់គត់។ដូចដែលអល់ឡោះទ្រង់មានព្រះបន្ទូលថា៖**

﴿وَمَآ أُمِرُوٓاْ إِلَّا لِيَعۡبُدُواْ ٱللَّهَ مُخۡلِصِينَ لَهُ ٱلدِّينَ حُنَفَآءَ﴾ [البينة 5]

"ហើយពួកគេមិនត្រូវបានគេបញ្ជាឱ្យធ្វើអ្វីក្រៅពីឱ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះ ដោយចិត្តស្មោះស និងត្រឹមត្រូវចំពោះទ្រង់ឡើយ" (គួរអាន ៩៨ : ៥) (អាល់ពៃយីណះ ៖ ៥)ហើយព្យាការីមូហាំម៉ាត់ ក៏បានមានប្រសាសន៏ថា៖

«إِنَّمَا الْأَعْمَالُ بِالنِّيَّاتِ، وَإِنَّمَا لِكُلِّ امْرِئٍ مَا نَوَى».

"ពិតប្រាកដណាស់ ទង្វើ(អាម៉ាល់)ទាំងឡាយអាស្រ័យទៅតាមគោលបំណង(នៀត) ហើយបុគ្គលគ្រប់រូបនឹងទទួលបានផល(ការតបស្នង) តាមអ្វីដែលខ្លួនប៉ងប្រាថ្នា"។

### ទីពីរ៖ ការប្រព្រឹត្តតាមព្យាការីមូហាំម៉ាត់

**ទាំងពាក្យសំដី និងទង្វើ។ ព្យាការីបានមានប្រសាសន៍ថា៖**

«مَنْ أَحْدَثَ فِي أَمْرِنَا هَذَا مَا لَيْسَ فِيهِ فَهُوَ رَدٌّ»

"បុគ្គលណាដែលបង្កើតអ្វីមួយថ្មីនៅក្នុងកិច្ចការសាសនារបស់យើង ដោយវាពុំមែនជាកិច្ចការដែលបានមកពីយើងទេ នោះ គឺនឹងត្រូវគេបដិសេធចោល"

«مَنْ عَمِلَ عَمَلًا لَيْسَ عَلَيْهِ أَمْرُنَا فَهُوَ رَدٌّ» [4].

"បុគ្គលណាដែលធ្វើទង្វើ(អាម៉ាល់)អ្វីមួយដោយវាពុំមែនជាកិច្ចការដែលយើងបានប្រើទេនោះ វានឹងត្រូវគេបដិសេធចោល"



[1] នោះគឺ៖ បំណងនៃកិច្ចគោរពសក្ការៈគឺសំដៅទៅកាន់ទ្រង់តែមួយគត់ ងាកចេញពីអ្វីដែលផ្សេងពីទ្រង់ (តាហ្វសៀរ អាសសាក់ទី : ទំព័រ ៥៣៨)

[2] (អាល់ពូខរី៖១, មូស្លីម៖១៩០៧)

[3](អាល់ពូខរី៖២៦៩៧, មូស្លីម៖១៧១៨)

HADIYAH



# ទីពីរ៖ ច្បាប់នៃការសិក្សាអំពីរបៀបនៃការធ្វើអុំរ៉ោះនិងច្បាប់បញ្ញត្តិរបស់វា

គប្បីលើអ្នកដែលមានបំណងចង់គោរពប្រណិប័តន៍ណាមួយទៅចំពោះអល់ឡោះ គឺត្រូវយកចិត្តទុកដាក់សិក្សាតាមការណែនាំរបស់ព្យាការីមូហាំម៉ាត់(សូមអល់ឡោះប្រទានពរជ័យ និងសន្តិភាពដលគាត់) ដើម្បីឱ្យការគោរពប្រណិប័តន៍របស់គាត់ស្របតាមស៊ុណ្ណះ(លំអាន)របស់ព្យាការី។ គាត់បានជំរុញមនុស្សគ្រប់គ្នាឱ្យដើរតាមការបង្រៀន និងការណែនាំរបស់គាត់។ អំពី ម៉ាលិក កូនលោក អាល់ហ៊ូវ៉ៃរីស្ស គាត់បាននិយាយថា៖ ព្យាការីមូហាំម៉ាត់ បានមានប្រសាសន៏ថា៖

«صَلُّوا كَمَا رَأَيْتُمُونِى أُصَلِّ» [5].

"ចូរពួកអ្នកសឡាត(ថ្វាយបង្គំ)ដូចដែលពួកអ្នកបានឃើញខ្ញុំសឡាត(ថ្វាយបង្គំ)"

អំពី ហ្ចាពៀរ បាននិយាយថា៖

«رَأَيْتُ النَّبِيَّ صلى الله عليه وسلم يَرْمِى عَلَى رَاحِلَتِهِ يَوْمَ النَّحْرِ وَيَقُولُ: لِتَأْخُذُوا مَنَاسِكَكُمْ, فَإِنِّي لاَأَدْرِى لَعَلِّي لَا أَحُجُّ بَعْدَ حَجَّتِي هَذِهِ» [6].

"ខ្ញុំបានឃើញព្យាការីមូហាំម៉ាត់ ﷺ គប់គោលខណៈលោកនៅលើជំនិះរបស់លោកក្នុងថ្ងៃបុណ្យហាជ្ជី ហើយលោកបានមានប្រសាសន៍ថា៖ ចូរពួកអ្នកទទួលយករបៀបនៃការធ្វើបុណ្យហាជ្ជីពីខ្ញុំ ព្រោះខ្ញុំមិនដឹងទេថា ខ្ញុំអាចបានមកធ្វើហាជ្ជីម្តងទៀតបន្ទាប់ពីការធ្វើហាជ្ជីរបស់ខ្ញុំលើកនេះនោះទេ"

[1](មូស្លីម៖១៧១៨)

# ទីបី៖ ឧត្តមភាពនៃការធ្វើអុំរ៉ោះ

## សម្រាប់ការធ្វើអុំរ៉ោះ មានគុណតម្លៃពីរគឺ៖

## គុណតម្លៃទូទៅ

និងគុណតម្លៃពិសេស គុណតម្លៃទូទៅ៖
អំពី អាពីហ៊ូរ៉យរ៉ោះ បាននិយាយថា៖ ព្យាការីមូហាំម៉ាត់ ﷺ បានមានប្រសាសន៍ថា៖

«الْعُمْرَةُ إِلَى الْعُمْرَةِ كَفَّارَةٌ لِمَا بَيْنَهُمَا، وَالْحَجُّ الْمَبْرُورُ لَيْسَ لَهُ جَزَاءٌ إِلَّا الْجَنَّةَ» [7]

(ការធ្វើអុំមរ៉ោះពីរដងគេនឹងជម្រុះចោលនូវបាបកម្ម នៅចន្លោះវាទាំងពីរ ហើយហាជ្ជីដែលគេទទួលយក គ្មានអ្វីតបស្នងចំពោះវាក្រៅពីឋានសួគ៌ឡើយ)

---

អំពី អាប់ឌុលឡោះ ពិន ម៉ាស្អូទ បាននិយាយថា៖ ព្យាការីមូហាំម៉ាត់ ﷺ បានមានប្រសាសន៍ថា៖

«تَابِعُوا بَيْنَ الْحَجِّ وَالْعُمْرَةِ، فَإِنَّهُمَا يَنْفِيَانِ الْفَقْرَ وَالذُّنُوبَ كَمَا يَنْفِي الْكِيرُ[8] خَبَثَ الْحَدِيدِ وَالذَّهَبِ وَالْفِضَّةِ، وَلَيْسَ لِلْحَجِّ الْمَبْرُورِ ثَوَابٌ إِلا الْجَنَّةُ» [9].

(ចូរពួកអ្នកធ្វើហាជ្ជី និងអុំរ៉ោះបន្ទាប់គ្នា ព្រោះវាទាំងពីរនឹងបំបាត់នូវភាពក្រីក្រ និងបាបកម្ម ដូចជាកន្លែងដុតដែកដែលដុតភាពកខ្វក់ចេញពីដែក មាស និងប្រាក់។ ហើយហាជ្ជីដែលគេទទួលយក គ្មានអ្វីតបស្នងផលបុណ្យចំពោះវាក្រៅពីឋានសួគ៌ឡើយ)

---

គុណតម្លៃពិសេសគឺនៅក្នុងខែរ៉ម៉ាឧន៖ អំពី អ៊ិបនូអាប់ហ្គាស ជាការពិតណាស់ ព្យាការីមូហាំម៉ាត់ ﷺ បានមានប្រសាសន៍ថា៖

«عُمْرَةٌ فِي رَمَضَانَ تَقْضِي حَجَّةً مَعِي»[10].

"ការធ្វើអុំរ៉ោះក្នុងខែរ៉ម៉ាឧន គឺដូចជាការធ្វើហាជ្ជីជាមួយខ្ញុំ"

---

[7](អាល់ពូខរី៖១៧៧៣, មូស្លីម៖១៣៤៩)

[8](អាត់តៀរមីហ្ស៊ី៖៨១០,អាន់ណាសាអ៊ី៖២៦៣១)

[9]កន្លែងដុតដែកនិងជាងដែក។អាត់តាំហ៊ីអ៊ិបនូអាប់ឌុលពើរ(១៥/១០២)

[10]គឺស្មើនឹងការធ្វើហាជ្ជីជាមួយខ្ញុំ។ ដូចដែលមាននៅក្នុងសេចក្តីរាយការណ៍ផ្សេងទៀត។

هدية
HADIYAH

# របៀបធ្វើអុំរ៉ោះ



# ទីមួយ៖ ក្បួនច្បាប់នៃមីកត

**មីកត**គឺជាកន្លែងទាំងឡាយដែលព្យាការីមូហាំម៉ាត់បានកំណត់ដើម្បីចាប់ផ្តើមនៀត (ប៉ង)អៀហរ៉ម  សម្រាប់អ្នកដែលមានបំណងចង់ធ្វើហាជ្ជី ឬអ៊ុំរ៉ោះ។ ជនណាដែលឆ្លងកាត់កន្លែងណាមួយនៃមីកតនោះដោយមានបំណងចង់ធ្វើហាជ្ជី ឬអ៊ុំរ៉ោះ គឺចាំបាច់ត្រូវនៀត(ប៉ង)អៀហរ៉មពីកន្លែងនោះ។ ដោយមិនត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់វាដោយមិនបានអៀហរ៉មឡើយ។

---

អ្នកដែលនៅជិតម៉ាក្កះ នោះកន្លែងនៀត(ប៉ង)អៀហរ៉មរបស់គេគឺកន្លែងរបស់គេ។ ដោយគេត្រូវនៀត(ប៉ង)អៀហរ៉មសម្រាប់ធ្វើហាជ្ជី និងអ៊ុំរ៉ោះ ពីទីនោះ។

---

ចំពោះប្រជាជនម៉ាក្កះ និងអ្នកដែលមានបំណងនៀត(ប៉ង)អៀហរ៉មពីទីនោះ៖ ពួកគេត្រូវនៀត(ប៉ង)អៀហរ៉មសម្រាប់ហាជ្ជីពីម៉ាក្កះ។រីឯអ៊ុំរ៉ោះវិញ ពួកគេត្រូវចេញទៅក្រៅទឹកដីហារ៉មហើយនៀត (ប៉ង)អៀហរ៉មពីទីនោះដូចជានៅកន្លែងតាន់អ៊ីម និងកន្លែងផ្សេងទៀត។ ហើយសម្រាប់អ្នកដែលជិះយន្តហោះ៖ គាត់ត្រូវនៀត (ប៉ង)អៀហរ៉មនៅពេលគាត់ទៅដល់កន្លែងដែលបានកំណត់សម្រាប់នៀត(ប៉ង) អៀហរ៉ម

---

នោះ។ ដូច្នេះគាត់ត្រូវរៀបចំនិងស្លៀកពាក់  អៀហរ៉មមុនពេលទៅដល់មីកត (កន្លែងដែលត្រូវនៀត(ប៉ង)អៀហរ៉ម) ហើយនៅពេលគាត់ទៅដល់នោះ គឺគាត់ត្រូវនៀត(ប៉ង)អៀហរ៉មភ្លាមៗ ដោយមិនអនុញ្ញាតឱ្យគាត់ពន្យារពេលរហូតដល់គាត់ចុះចតនៅអាកាសយានដ្ឋានឡើយ ហើយគាត់អាចធ្វើការតាល់ពីយ៉ះមុនទៅដល់មីកត ព្រោះខ្លាចមិនទាន់ ដោយសារល្បឿនលឿននៃយន្តហោះ។

هدية
HADIYAH

# ទីពីរ៖ របៀបធ្វើអ៊ុំរ៉ោះ និងក្បួនច្បាប់របស់វា

**ច្បាប់បានចែងចំពោះអ្នកដែលចង់(ប៉ង)អៀហរ៉មធ្វើអ៊ុមរ៉ោះ**
គឺគេត្រូវអនុវត្តដូចខាងក្រោម៖
ងូតទឹក ដែលវាគឺជាស៊ុណ្ណះដែលត្រូវបានជំរុញណែនាំសម្រាប់បុរស និង ស្ត្រី សូម្បីតែស្ត្រីដែលមករដូវ និងស្ត្រីក្រោយសម្រាលកូន។

---

ប្រើទឹកអប់ដែលល្អបំផុតដែលគេមាននៅលើក្បាល និងពុកចង្ការរបស់គេ ហើយគ្មានបញ្ហាអ្វីឡើយប្រសិនបើមានសល់ស្លាកស្នាមបន្ទាប់ពីអៀហរ៉ម។ ចំពោះស្ត្រីវិញ គឺហាមប្រើទឹកអប់ ដើម្បីកុំឱ្យបុរសដទៃស្រង់ក្លិនរបស់នាង។



ដែលជាក្រណាត់ពីរដុំ(សម្រាប់រុំផ្នែកខាងលើ និងខាងក្រោម) ហើយតាមស៊ុណ្ណះគួរប្រើក្រណាត់ពណ៌សដែលស្អាត ឬថ្មី។ ចំណែកស្ត្រីអាចស្លៀកអ្វីក៏បានដែលនាងពេញចិត្តដោយមិនបង្ហាញភាពឆើតឆាយ ហើយជៀសវាងពាក់នីកប(ក្រណាត់បិទមុខ)

HADIYAH هدية

និងពាក់ស្រោមដៃ ដោយគេអាចគ្របមុខ និងដៃរបស់នាងជាមួយអ្វីផ្សេងទៀតបាន។
ឡាប់បានចែងគួគម្បីសឡាតមុននឹងនៀត(ប៉ង)អៀហរ៉ម ជាសឡាតហ្វើរទូ ឬសឡាតស៊ូណិត តែមិនមែនវ៉ាជិប(ចាំបាច់)នោះទេ។
បន្ទាប់មក ត្រូវពោលថា៖ لَبَّيْكَ اللَّهُمَّ عُمْرَةً (ឡាប់ពៃកល់ឡ ហ៊ុមម៉ាអ៊ុំរ៉ោះ)។ ហើយបើសិនជាគេធ្វើអ៊ុំរ៉ោះឱ្យអ្នកដទៃ គឺត្រូវពោលថា៖ لَبَّيْكَ اللَّهُمَّ عُمْرَةً عَنْ فُلَانٍ (ឡាប់ពៃកល់ឡ ហ៊ុមម៉ាអ៊ុំរ៉ោះអាន"ឈ្មោះអ្នកដែលគេចង់ធ្វើឱ្យ")។

---

ប្រសិនបើអ្នកនៀត(ប៉ង)អៀហរ៉ម ខ្លាចមានឧបសគ្គដែលនឹងរារាំងគេពីការបញ្ចប់ការធ្វើអ៊ុំរ៉ោះនោះ គេ គួរ តែ ដា ក់ ល ក្ខ ខ ណ្ឌ ពេ ល នៀ ត ( ប៉ ង ) អៀ ហ រ៉ ម នោះ ដោ យ សូ ត្រ ថា ៖ (لَبَّيْكَ اللَّهُمَّ عُمْرَةً، وَإِنْ حَبَسَنِي حَابِسٌ فَمَحِلِّي حَيْثُ حَبَسْتَنِي)" ឡាប់ពៃកល់ឡ ហ៊ុមម៉ាអ៊ុំរ៉ោះ វ៉ាអិនហាប៉ាសានី ហាពីសុន វ៉ាម៉ាហាល់លី ហៃស៊ូហាប៉ាសតានី " ។

---

ប្រសិនបើគេបានដាក់លក្ខខណ្ឌហើយមានអ្វីមួយដែលរារាំងគេពីការបញ្ចប់ការធ្វើអ៊ុំរ៉ោះ នោះគេអាចបញ្ចប់អៀហរ៉មនៅពេលនោះ ឬកន្លែងនោះបាន។
បន្ទាប់មកគេគប្បីសូត្រតាល់ពីយ៉ះឱ្យបានច្រើន ដោយពោលថា៖ :

---

(لَبَّيْكَ اللَّهُمَّ لَبَّيْكَ، لَبَّيْكَ لَا شَرِيكَ لَكَ لَبَّيْكَ، إِنَّ الْحَمْدَ وَالنِّعْمَةَ لَكَ وَالْمُلْكَ، لَا شَرِيكَ لَكَ)១
ចំពោះបុរសត្រូវសូត្រវាដោយបន្លឺសំឡេង និងស្ត្រីក៏ដូចគ្នាដែរនៅពេលដែលគ្មានវត្តមានបុរសដែលមិនមែនជាមួសរ៉ម។ហើយគប្បីលើគេសូត្រតាល់ពីយ៉ះឱ្យបានច្រើនជាពិសេសនៅពេលដែលផ្លាស់ប្តូរកន្លែង និងពេលវេលា ដូចជានៅពេលដែលគេឡើងទៅកាន់ទីខ្ពស់ ឬចុះទៅទីទាប ឬពេលដែលយប់ ឬថ្ងៃជិតចូលមកដល់។
ការសូត្រតាល់ពីយ៉ះ គឺគប្បីធ្វើវាចាប់តាំងពីផ្តើមនៀត(ប៉ង)អៀហរ៉មដើម្បីធ្វើអ៊ុំរ៉ោះរហូតដល់ចាប់ផ្តើមតវ៉ាហ្វ(ដើរប្រទក្សិណជុំវិញកាក់ហ្បះ)។

---

អ្នកដែលកំពុងស្ថិតនៅក្នុងអៀហរ៉ម ត្រូវតែប្រុងប្រយ័ត្នកុំឱ្យធ្លាក់ចូលទៅក្នុងប្រការដែលគេបានហាមឃាត់ណាមួយក្នុងអំឡុងពេលនោះ រហូតដល់គេត្រូវបានបញ្ចប់រួចរាល់ពីអៀហរ៉មជាមុនសិន។

---

[11]អត្ថន័យនៃពាក្យតាល់ពីយ៉ះគឺ៖ «لَبَّيْكَ» គឺឆ្លើយតបនឹងបទបញ្ជារបស់ទ្រង់ និងគោរពប្រណិបតន៍របស់គេចំពោះទ្រង់ ជាបន្តបន្ទាប់។ «إِنَّ الْحَمْدَ وَالنِّعْمَةَ لَكَ وَالْمُلْكَ» គឺជាការសរសើរដ៏ពេញលេញទៅចំពោះទ្រង់ ដោយក្តីស្រឡាញ់ និងការគោរពតម្កើង ដែលទ្រង់ប្រទានដល់អ្នកបម្រើរបស់ទ្រង់នូវលាភសក្ការៈជាច្រើនដែលគេចង់បាន និងបញ្ចៀសពីអ្វីដែលគេមិនពេញចិត្ត។ ហើយទ្រង់គឺជាស្តេចតែមួយអង្គគត់ដែលមហាខ្លាំងក្លា។ «لَا شَرِيكَ لَكَ» គឺគ្មាននរណាម្នាក់ដែលរួចចំណែកជាមួយទ្រង់នូវអ្វីដែលជាកំលាក់សម្រាប់ទ្រង់នោះឡើយចំពោះលក្ខណៈដ៏ល្អឥតខ្ចោះរបស់ទ្រង់ ដោយទ្រង់តែម្នាក់គត់ដែលជាស្តេច ជាអ្នកបង្កើត គ្រប់គ្រង និងត្រូវគេគោរពសក្ការៈ។ សេចក្តីសង្ខេប (22 96)
១ مجموع فتاوى ورسائل العثيمين

هدية HADIYAH

# ទីបី៖ របៀបតវ៉ាហ្វ
# (ការដើរប្រទក្សិណជុំវិញកាក់ហ្ពះ)

នៅពេលដែលគេចូលដល់ម៉ាស្ជិតអាល់ហារ៉ម គេគប្បីឈានជើងស្តាំចូលមុន និងត្រូវសូត្រទូអាពេលចូលម៉ាស្ជិត ហើយទូអាដែលត្រឹមត្រូវនោះសូត្រថា៖ "اللَّهُمَّ افْتَحْ لِي أَبْوَابَ رَحْمَتِكَ" ។ វាជាទូអាដែលគប្បីសូត្វានៅពេលចូលម៉ាស្ជិតទាំងឡាយ មិនសម្រាប់តែម៉ាស្ជិតអាល់ហារ៉មឡើយ។
ពេលដែលគេទៅដល់កាក់ហ្ពះ

---

គឺត្រូវបញ្ឈប់ការសូត្រតាល់ពីយ៉ះមុននឹងគេចាប់ផ្តើមតវ៉ាហ្វ។ ហើយចំពោះបុរស គេគប្បីតវ៉ាហ្វដោយបើកស្មាស្តាំ ដោយត្រូវដាក់ក្រណាត់អៀហរ៉មពីក្រោមក្លៀកខាងស្តាំ និងជាយអៀហរ៉មពីលើស្មាឆ្វេង។ នៅពេលដែលគេបញ្ចប់តវ៉ាហ្វ គឺត្រូវគ្របស្មារបស់គេវិញ ពីព្រោះថាការបើកស្មាសម្រាប់តែពេលតវ៉ាហ្វប៉ុណ្ណោះ។
ដើម្បីចាប់ផ្តើមតវ៉ាហ្វ គេគប្បីដើរឆ្ពោះទៅកាន់ហាជើរ៉ុលអាសវ៉ាត់ (ថ្មខ្មៅ) ហើយឱ្យសាឡាមដោយយកដៃស្តាំប៉ះលើវា រួចថើបវា។ តែប្រសិនបើមិនមានភាពងាយស្រួលក្នុងការធ្វើដូច្នេះទេ គឺត្រូវបែរខ្លួនទៅកាន់វា រួចលើកដៃស្តាំតម្រង់ទៅកាន់វាគឺគ្រប់គ្រាន់ហើយ។ ជាការល្អប្រសើរ គឺមិនត្រូវប្រជ្រៀតគ្នា ដែលបង្កជាផលប៉ះពាល់ និងមានការលំបាកដល់អ្នកដទៃនោះឡើយ។
ហើយនៅពេលឱ្យសាឡាមដោយយកដៃស្តាំប៉ះលើហាជើរ៉ុលអាស់វ៉ាត់ ឬលើកដៃតម្រង់ទៅវានោះគឺគប្បីសូត្រថា៖ (اللَّهُ أَكْبَرُ) (អល់ឡហ៊ូអឹកពើរ) ។
បន្ទាប់មកត្រូវចាប់ផ្តើមពីស្តាំដោយដាក់កាក់ហ្ពះនៅខាងឆ្វេងដៃនៅពេលទៅដល់ជ្រុងយ៉ាម៉ានី គេគប្បីស្ទាបវា តែមិនតម្រូវឲ្យថើបឡើយ។ តែបើមិនមានភាពងាយស្រួលក្នុងការធ្វើដូចនោះទេ ចូរកុំប្រជ្រៀតគ្នាដើម្បីធ្វើវា ហើយមិនតម្រូវឲ្យលើកដៃតម្រង់ទៅវាពីចម្ងាយនោះទេ។

هدية
HADIYAH



ហើយនៅចន្លោះរវាងជ្រុងយ៉ាម៉ានិ និងហាជេរ៉ុល
អាសវ៉ាត់ គេគប្បីសូត្រថា៖
(رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً وَفِي الْآخِرَةِ حَسَنَةً وَقِنَا
عَذَابَ النَّارِ) ។
រាល់ពេលដែលគេឆ្លងកាត់ហាជើរ៉ុលអាសវ៉ាត់គឺ
ត្រូវលើកដៃតម្រង់តៅកាន់វា ហើយសូត្រ
(اللَّهُ أَكْبَرُ)(អល់ឡហ៊ូអឹកពើរ)។ហើយនៅពេល
តវ៉ាហ្វគេអាចសុំទូអា ហ្ស៊ីកៀរ និងសូត្រអាល់គួរ
អានតាមដែលគេពេញចិត្ត។ តាមស៊ុណ្ណះចំពោះ
បុរសគប្បីរត់តិចៗនៅបីជុំដំបូង រីឯបួនជុំ
ចុងក្រោយមិនត្រូវរត់តិចៗនោះទេ គឺដើរធម្មតា
។នៅពេលដែលគេតវ៉ាហ្វបានគ្រប់ប្រាំពីរជុំ
ហើយ  គេត្រូវដើរឆ្ពោះ\ទៅកាន់ផ្នែកខាងក្រោយ
នៃម៉ាកមអ៊ីព្រហ៊ីម ហើយសូត្រថា៖

﴿وَٱتَّخِذُواْ مِن مَّقَامِ إِبْرَٰهِـۧمَ مُصَلًّى﴾،

(អាល់ហ្គាក៏រ៉ោះ៖១២៥) ហើយសឡាតពីររ៉ក្អាត់នៅទីនោះប្រសិនបើមានភាពងាយស្រួល ឬកន្លែងណាក៏បានក្នុងម៉ាស្ជិតអាល់ហារ៉ម ប្រសិនបើមានការលំបាក ឬចង្អៀត។ក្នុងរ៉ក្អាត់ទីមួយ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ គេត្រូវសូត្រស៊ូរ៉ោះ៖

﴿قُلْ يَـٰٓأَيُّهَا ٱلْكَـٰفِرُونَ﴾

អាល់កាហ្វីរូន (អាល់កាហ្វីរូន៖១) ក្នុងរ៉ក្អាត់ទីពីរ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ គេត្រូវសូត្រស៊ូរ៉ោះ៖

﴿قُلْ هُوَ ٱللَّهُ أَحَدٌ﴾.

អាល់អៀខ្លើស ។ (អាល់អៀខ្លើស៖១)

**ទីបួន៖ របៀបសាអ៊ី**

ក្រោយតវ៉ាហ្វ និងសឡាតរួចរាល់ គេត្រូវចាកចេញទៅកាន់កន្លែងសាអ៊ី។ នៅពេ ដែលគេទៅជិតដល់ភ្នំសហ្វា គេត្រូវសូត្រថា៖

﴿إِنَّ ٱلصَّفَا وَٱلْمَرْوَةَ مِن شَعَآئِرِ ٱللَّهِ﴾

អាល់ហ្គាក៏រ៉ោះ៖១៥៨) រួចពោលថា៖"أَبْدَأُ بِمَا بَدَأَ اللَّهُ بِهِ" ។

هدية
HADIYAH

«أَبْدَأُ بِمَا بَدَأَ اللهُ بِهِ».
បន្ទាប់មក ត្រូវឡើងលើភ្នំសហ្វា រួចតម្រង់ទៅកាន់កាក់ហ្ពះ លើកដៃទាំងពីរសូត្រ (اللَّهُ أَكْبَرُ) បីដងរួចសូត្រថា៖
(لَا إِلَهَ إِلَّا اللَّهُ وَحْدَهُ لَا شَرِيكَ لَهُ, لَهُ الْمُلْكُ وَلَهُ الْحَمْدُ, وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ, لَا إِلَهَ إِلَّا اللَّهُ وَحْدَهُ, أَنْجَزَ وَعْدَهُ, وَنَصَرَ عَبْدَهُ, وَهَزَمَ الْأَحْزَابَ وَحْدَهُ)

---

សូត្រវាចំនួនបីដង។ និងបួងសួងសុំទូអានូវអ្វីដែលគេប្រាថ្នា។
«ثُمَّ دَعَا بَيْنَ ذَلِكَ قَالَ مِثْلَ هَذَا ثَلَاثَ مَرَّاتٍ
لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ, لَهُ الْمُلْكُ وَلَهُ الْحَمْدُ, وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ, لَا إِلَهَ إِلَّا اللهُ وَحْدَهُ, أَنْجَزَ وَعْدَهُ, وَنَصَرَ عَبْدَهُ, وَهَزَمَ الْأَحْزَابَ وَحْدَهُ»،

---

បន្ទាប់មក ត្រូវចុះពីភ្នំសហ្វា រួចដើរតម្រង់ទៅកាន់ភ្នំម៉ារវ៉ះ។ លុះពេលគេទៅដល់បង្គោលបៃតងទាំងពីរ ចំពោះបុរសគប្បីត្រូវរត់តិចៗនៅចន្លោះបង្គោលទាំងពីរនោះ ចំណែកឯស្ត្រីវិញ គឺត្រូវដើរធម្មតា។
នៅពេលទៅដល់ភ្នំម៉ារវ៉ះ គឺត្រូវតម្រង់ទៅកាន់កាក់ហ្ពះ ហើយលើកដៃទាំងពីរ រួចសូត្រដូចអ្វីដែលគេបានសូត្រនៅភ្នំសហ្វាដែរ។
(កថាខណ្ឌលេខ ២)

---

បន្ទាប់មក ត្រូវចុះពីភ្នំម៉ារវ៉ះ រួចដើរសំដៅទៅកាន់ភ្នំសហ្វាវិញ។ លុះពេលគេទៅដល់បង្គោលបៃតងទាំងពីរចំពោះបុរសគប្បីត្រូវរត់តិចៗនៅចន្លោះបង្គោលទាំងពីរនោះ។

---

គេត្រូវធ្វើបែបនេះ រហូតដល់គ្រប់ប្រាំពីរជុំ។ ពេលចេញពីភ្នំសហ្វាទៅដល់ភ្នំម៉ារវ៉ះ រាប់ថាមួយជុំ ហើយពេលត្រឡប់មកវិញ រាប់ថាមួយជុំទៀត។ ក្នុងពេលសាអ៊ី ស៊ូណិតបង្កើននូវការហ្ស៊ីកៀរ សូត្រអាល់គួរអាន និងសុំទូអាតាមដែលគេពេញចិត្ត។

HADIYAH هدية



# ទីប្រាំ៖ របៀបនៃការកោរ ឬកាត់សក់

នៅពេលដែលអ្នកធ្វើអ៊ុំរ៉ោះបានបញ្ចប់ការតវ៉ាហ្វនិងសាអ៊ីរួចរាល់គេត្រូវកាត់សក់ឬកោរសក់។ដោយស៊ុណ្ណះគប្បីត្រូវកាត់ឬកោរសព្វពេញក្បាលរបស់គេ សម្រាប់បុរស។

ការកោរ គឺប្រសើរជាងកាត់។លើកលែងតែគេធ្វើហាជ្ជី ហើយថ្ងៃធ្វើហាជ្ជីខិតជិតមកដល់ដោយខ្លាចសក់ដុះមិនទាន់នោះកាត់សក់ខ្លីគឺជាការល្អ។ ចំណែកឯស្ត្រីវិញគឺត្រូវកាត់សក់របស់នាងប្រវែងមួយថ្នាំងដៃ។



[12] រាយការណ៍ដោយ អ៊ីមុាំ មូស្លីម លេខ ១២១៨

## បម្រាមទាំងឡាយនៃអៀហរ៉ម

បម្រាមទាំងឡាយនៃអៀហរ៉មមានដូចជា៖
កោរ ឬកាត់ ឬដកសក់និងរោមនៃផ្នែកណាមួយនៃរាងកាយ។
កាត់ក្រចកដៃ ឬក្រចកជើង។
គ្របក្បាលនឹងអ្វីម្យ៉ាងជាប់នឹងក្បាល ដូចជា៖ សាល់ មួក ក្រណាត់ កន្សែងឬអ្វីផ្សេងពីនេះ។រីឯការគ្របក្បាលពីខាងល(មិនជាប់ផ្ទាល់នឹងក្បាល)ដូចជាដំបូលយានជំនិះ ឬឆ័ត្រជាដើម គឺគ្មានបញ្ហាឡើយ។ នេះជាបម្រាមដែលគេហាមឃាត់ចំពោះតែបុរសប៉ុណ្ណោះ។

---

ស្លៀកសម្លៀកបំពាក់មានថ្នេរដែលគេតែងពាក់វាជាធម្មតា ដូចជា៖ អាវខោ អាវក្រៅ ស្រោមជើង និងស្រោមដៃជាដើម។ នេះជាបម្រាមដែលគេហាមឃាត់ចំពោះតែបុរសប៉ុណ្ណោះ។ ចំណោកស្រ្តីវិញគឺត្រូវបាហាមឃាត់ដូចជា៖ពាក់ស្បៃគ្របមុខនិងបិទមុខ៖ស្រ្តីត្រូវបើកមុខរបស់ខ្លួន (ក្នុងពេលស្ថិតក្នុងតំណមអៀហរ៉ម) លើកលែងតែពេលដែលមានបុរសដទៃ(ដែលអាចរៀបការនឹងគ្នាបាន)ដើរកាត់ប៉ុណ្ណោះ។ ពេលនោះ នាងអាចគ្របមុខរបស់នាងបាន ហើយបើទោះជាក្រណាត់គ្របមុខនោះប៉ះ

---

ស្បែកមុខរបស់នាងក៏ដោយក៏គ្មានបញ្ហាអ្វីដែរ។
ការពាក់ស្រោមដ ហើយនៅតែពេលដែលមានបុរសដទៃ (ដែលអាចរៀបការនឹងគ្នាបាន) ដើរកាត់ឬនៅជិតគឺនាងត្រូវដាក់ដៃចូលទៅខាងក្នុងអាវរបស់នាង។
ប្រើប្រាស់គ្រឿងក្រអូប និងទឹកអប់មិនថាលើសម្លៀកបំពាក់ ឬលើខ្លួនប្រាណឡើយ។
សម្លាប់សត្វ ឬប្រមាញ់សត្វទោះបីជាមិនសម្លាប់វាក៏ដោយ។
ធ្វើការភ្ជាប់ពាក្យ មិនថាសម្រាប់ខ្លួនឯង ឬអ្នកដទៃនោះទេ។
រៀបអាពាហ៍ពិពាហ៍(អាកត់នីកាស)។ ការប៉ះពាល់គ្នាប្តីប្រពន្ធ ដូចជាឱបថើប ស្ទាបអង្អែលដោយមា ចំណង់តណ្ហា។ រួមមេត្រីរវាងប្តីប្រពន្ធ។

ស្បែកមុខរបស់នាងក៏ដោយក៏គ្មានបញ្ហាអ្វីដែរ។   ការពាក់ស្រោមដ
ហើយនៅតែពេលដែលមានបុរសដទៃ(ដែលអាចរៀបការនឹងគ្នាបាន)
ដើរកាត់ឬនៅជិតគឺនាងត្រូវដាក់ដៃចូលទៅខាងក្នុងអាវរបស់នាង។
ប្រើប្រាស់គ្រឿងក្រអូប និងទឹកអប់មិនថាលើសម្លៀកបំពាក់ ឬ
ខ្លួនប្រាណឡើយ។
សម្លាប់សត្វ ឬប្រមាញ់សត្វទោះបីជាមិនសម្លាប់វាក៏ដោយ។
ធ្វើការភ្ជាប់ពាក្យ មិនថាសម្រាប់ខ្លួនឯង ឬអ្នកដទៃនោះទេ។
រៀបអាពាហ៍ពិពាហ៍(អាកត់នីកាស)។ ការប៉ះពាល់គ្នាប្ដីប្រពន្ធ ដូចជា
ឱបថើប ស្ទាបអង្អែលដោយមា ចំណង់តណ្ហា។ រួមមេត្រីរវាងប្ដីប្រពន្ធ។



هدية
HADIYAH



# ការសង្ខេបអំពីរបៀបធ្វើអ៊ុំរ៉ោះ (មាននៅលើក្របមុខ ឬខាងចុងទំព័រ)

## ងូតទឹក

ប្រើប្រាស់ទឹកអប់។ ស្លៀកសម្លៀកបំពាក់អៀហរ៉ម។

អៀហរ៉មគឺជាការនៀ

---

(ប៉ង)ចូលធ្វើកាតព្វកិច្ច(ការធ្វើហាជ្ជី ឬអ៊ុំរ៉ោះ)។ តាល់ពីយ៉ះ

---

តវ៉ាហ្វជុំវិញកាក់ហ្ពះ

សឡាតពីររ៉ក្អាត់ខាងក្រោយម៉ាកមអ៊ីព្រហ៊ីម។

សាអ៊ីរវាងភ្នំសហ្វានិងភ្នំម៉ាររ៉ះ។

កោរសក់ ឬកាត់សក់។

وَاللَّهُ أَعْلَمُ، وَصَلَّى اللَّهُ وَسَلَّمَ عَلَى نَبِيِّنَا مُحَمَّدٍ

HADIYAH هدية

# Index


| | |
|---|---|
| សេចក្ដីសង្ខេបអំពីរបៀបនៃការធ្វើអ៊ុំរ៉ោះ និងក្បួនច្បាប់របស់វា | 2 |
| សេចក្ដីផ្ដើម | 2 |
| ទីមួយ៖ លក្ខខណ្ឌនៃការទទួលយកកិច្ចគោរពសក្ការៈ | 3 |
| ទីពីរ៖ ច្បាប់នៃការសិក្សាអំពីរបៀបនៃការធ្វើអ៊ុំរ៉ោះ និងច្បាប់បញ្ញត្តិរបស់វា | 4 |
| ទីបី៖ ឧត្តមភាពនៃការធ្វើអ៊ុំរ៉ោះ | 5 |
| របៀបធ្វើអ៊ុំរ៉ោះ | 6 |
| ទីមួយ៖ ក្បួនច្បាប់នៃមីកត | 7 |
| ទីពីរ៖ របៀបធ្វើអ៊ុំរ៉ោះ និងក្បួនច្បាប់របស់វា | 8 |
| ទីបី៖ របៀបតវ៉ាហ្វ(ការដើរប្រទក្សិណជុំវិញកាក់ហ្ពះ) | 10 |
| ទីបួន៖ របៀបសាអ៊ី | 11 |
| ទីប្រាំ៖ របៀបនៃការកោរ ឬកាត់សក់ | 13 |
| បម្រាមទាំងឡាយនៃអៀហរ៉ម | 14 |
| ការសង្ខេបអំពីរបៀបធ្វើអ៊ុំរ៉ោះ(មាននៅលើក្របមុខ ឬខាងចុងទំព័រ) | 16 |

HADIYAH
HAJI & MU'TAMR'S GIFT

هدية
هدية الحاج والمعتمر

www.hadiyah.org.sa